លេខ ៦៥ អយកម. ចនម. ចុះថ្ងៃទី ០២ - ០១ - ១៩៩៦

_តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១ :** អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និង កីឡាខេត្តបន្ទាយមានជ័យ ផ្ដាច់សាលាបឋមសិក្សាអំពិលព្រាង ឧបសម្ព័ន្ធសាលាបឋមសិក្សាស្រះថែង ក្នុងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ មកជា « សាលាបឋមសិក្សា អំពិលព្រាង » ពេញលក្ខណៈ ចាប់ពីឆ្នាំសិក្សា ១៩៩៦ នេះតទៅ ។

**ប្រការ ២ :** សាលាបឋមសិក្សាអំពិលព្រាង ត្រូវដឹកនាំដោយនាយក ១ រូប និង នាយករង ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់បឋមសិក្សា ។

**ប្រការ ៣ :** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** ប្រធានមន្ទីរ ក្រសួងអប់រំ យុវជន និង កីឡា ប្រធាននាយកដ្ឋានផែនការហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្ត បន្ទាយមានជ័យ ប្រធានការិយាល័យអប់រំ យុវជន និង កីឡា ស្រុកស្វាយចេក នាយកសាលាបឋមសិក្សា ស្រះថែង នាយកសាលាបឋមសិក្សា អំពិលព្រាង មានភារកិច្ចអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**តា សាហាន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ១៩៧ អយក. ប្រក**

**ស្ដីពីការផ្ដាច់សាលាឧបសម្ព័ន្ធមកជាសាលាពេញលក្ខណៈ**

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

–បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ - ៧ - ១៩៩៤

–បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រ.ច ចុះថ្ងៃទី ២០ - ១១ - ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ

–បានឃើញ អនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ២៥ - ១០ - ១៩៨៦ ស្តីពីការកំនត់បទដ្ឋាន ប្រើប្រាស់ក្របខ័ណ្ឌសំរាប់អង្គភាពអប់រំនានា

–បានពិនិត្យលិខិតស្នើសុំ របស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្តបន្ទាយមានជ័យ លេខ ៦៤ អយក១. ចទម ចុះថ្ងៃទី ០២ - ០១ - ១៩៩៦

_តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១ :** អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និង កីឡាខេត្តបន្ទាយមានជ័យ ផ្តាច់ :

១–សាលាឧបសម្ព័ន្ធ ម៉ៅ ចេញពី សាលាបឋមសិក្សា ផ្គាំ មកជាសាលាបឋមសិក្សា ម៉ៅ ពេញលក្ខណៈវិញ ។

២–សាលាឧបសម្ព័ន្ធ យាងវៀន ចេញពី សាលាបឋមសិក្សា ផ្គាំ មកជាសាលាបឋមសិក្សាយាងវៀនពេញលក្ខណៈវិញ ។

**ប្រការ ២ :** សាលាបឋមសិក្សា ដូចមានរាយនាមខាងលើ ត្រូវដឹកនាំដោយនាយក ១ រូប និង នាយករង ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋាន ក្របខ័ណ្ឌសំរាប់ សាលាបឋមសិក្សា ។

**ប្រការ ៣ :** នាយក និង នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ ៤** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥** : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជន និង កីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា ប្រធានមន្ទីរ អប់រំ យុវជន និង កីឡា ខេត្តបន្ទាយមានជ័យ ប្រធានការិយាល័យអប់រំ យុវជន និង កីឡា ស្រុកស្វាយចេក នាយកសាលាបឋមសិក្សា ម៉ៅ និង នាយកសាលាបឋមសិក្សា យាងវៀន មានភារកិច្ចអនុវត្តប្រកាសនេះ ។

ហត្ថលេខា និង ត្រា

**តុល ឡោះ**

* * *

# ៥—ទីស្តីការរដ្ឋមន្ត្រី ក្រសួងសុខាភិបាល

# ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៦

## ប្រកាសលេខ ១២០ ស.នបដ

## ស្តីពីការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងការិយាល័យសុខាភិបាលស្រុក

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១_១១_១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសារាចរលេខ ៨៥ ស.កកទ ចុះថ្ងៃទី ២៥_៧_១៩៩៥ របស់ក្រសួងសុខាភិបាលស្តីពីការកសាង និង អនុវត្តផែនការគ្របដណ្តប់សុខាភិបាលស្រុក_ឃុំ
- បានឃើញសារាចរលេខ ១៩០ ចុះថ្ងៃទី ១៣_១២_១៩៩៤របស់ក្រសួងសុខាភិបាលស្តីពីការតែងតាំងប្រធានការិយាល័យសុខាភិបាលស្រុក